# ក្បួនទំនាយបុរាណ

***សិទ្ធិការិយៈ*** លោកថា បើបុរសស្ត្រីឯណា អ្នកត្រាច់ចរទៅកាន់ទីនានា ឬចង់ឱ្យដឹងច្បាស់នូវដំណើរល្អ ឬអាក្រក់ដែលនឹងមានកើតឡើងដល់ខ្លួន និងញាតិមិត្តដែលស្ថិតនៅជិតឆ្ងាយ ឬរបស់អន្តរាយដោយចោរលួច ចោរប្លន់ ឬក៏បាវព្រាវមនុស្សរត់ចេញ គេចទៅទិសដ៏ទៃៗ ត្រូវឱ្យចាំថ្ងៃនិងពេលវេលា ដែលយាត្រាចេញទៅ ឬថាបណ្តាលឱ្យកើតហេតុអាក្រក់-ល្អនោះ ឱ្យយកមកផ្ទួរផ្ទៀបមើលក្បួនតម្រានេះ ទោះបីខ្នើតឬរនោចត្រូវគ្នានិងយាមណា លោកឱ្យមើលតាមខ្ទង់លេខទំនាយដូចតទៅនេះ ៚

## នេះគឺយាមបញ្ចុះ

| ខ្នើត ឬ រនោច | ១ - ៦ - ១១ | ២ - ៧ - ១២ | ៣ - ៨ ១៣ | ៤ - ៩ ១៤ | ៥ - ១០ - ១៥ |
|---|---|---|---|---|---|
| ពេលព្រឹក | មហោសុភា | យាមកាលា | យាមសី | ព្រហ្មា | វិសុទ្ធជន្ម |
| ពេញពន្លឺធំ | វិសុទ្ធជន្ម | មហោសុភា | យាមកាលា | យាមសី | ព្រហ្មា |
| ថ្ងៃត្រង់ | ព្រហ្មា | វិសុទ្ធជន្ម | មហោសុភា | យាមកាលា | យាមសី |
| រសៀល | យាមសី | ព្រហ្មា | វិសុទ្ធជន្ម | មហោសុភា | យាមកាលា |
| ពេលល្ងាច | យាមកាលា | យាមសី | ព្រហ្មា | វិសុទ្ធជន្ម | មហោសុភា |

***ពិធីរាប់ដេញរកាមើលៈ*** បើថ្ងៃ ១ កើត ឬ ១ រោច ។ល។ ១៥ កើត ឬ ១៥ រោច នៅលើយាមណា ត្រូវមើលតាមខ្ទង់ ហើយទាយតាមនោះចុះ... ។ ឧទាហរណ៍: ១ កើត ... ១ រោច ។ល។ ១៥ កើត ... ១៥ រោច ។ល។

១. បើនៅលើយាម ***មហោសុភា*** ទោះនិងយាត្រាទៅជួបមនុស្ស សម្បុរសលឿង ស្លៀកពាក់សំពត់ខោអាវ ស្អាតរីករាយឱ្យលាភច្រើនសណ្ឋាន ។ បើទៅរកចៅហ្វាយនាយតាមផ្លូវការ ចេញផុតពីឋាននិងមានលាភយ៉ាងគាត់ចិត្ត ។ បើគេប្រាប់ដំណឹងអ្វីផ្សេងៗថាល្អ គឺពិតជាល្អមែនកុំសង្ស័យ, បើគេប្រាប់ថាអាក្រក់យ៉ាងណាៗ ទាយថាៈ ពាក្យនោះកុហក់ទេ ។ បើមើលពីរបស់បាត់វិញទាយថាៈ មនុស្សសម្បុរស លួចយកទៅលាក់ទុក ខាងទិសព្យាសាន លោកពោលថានឹង ឃើញវិញមិនបាត់ទេ ។ បើបាវព្រាវ ឬមនុស្សប្រុសស្រីវារត់ចេញគឺវាទៅនៅអាស្រ័យផ្ទះគេខាងទិសបូព៌ លោកថាមិនបាត់ទេ ។ ប៉ុន្តែបើវា ទៅទិសឧត្តរ មានមនុស្សឃាត់ទុក, បើសួរគេៗប្រាប់ថា គ្មានឃើញទេ ។ បើសិនជារកមើល ពីការឈឺថ្កាត់វិញ ទាយថាមានខ្មោចយាយី ឱ្យខំបន់ស្រន់ទៅទើបជា ។ បើទៅជួញប្រែ ឬ លក់ដូរ និងបានកម្រៃក្រាសក្រួនជូនបំណាង របស់សលឿងត្រូវគេឱ្យដល់យើង ជាមិនខានឡើយ ។ បើជល់មាន់ មាន់សឈ្នះមាន់ខ្មៅ ឬមាន់ពណ៌ផ្សេងៗទៀត បើមើលពិធីដំណើរថា ពេលណានឹងត្រឡប់មកវិញ ត្រូវយាម ***មហោសុភា*** លោកថាៈ មកក្នុងថ្ងៃនេះឯង បើពុំនោះនឹងមកថ្ងៃស្អែក ។ នេះជាយាម ***មហោសុភា*** ។

២. បើត្រូវលើ ***យាមកាលា*** ទោះបីលាទៅស្ថាននានា មុខជាជួបនឹងសត្រូវធ្វើបាប បណ្តាលអោយក្រោធខឹង ជេរផ្តាសារគ្នា បើពុំនោះទេ អ្នកទៅជាមួយមានកើតវិវាទគ្នាឯង ។ បើសិនជាបានវត្ថុអ្វីៗ វត្ថុនោះពណ៌ស ។ បើប្រាប់ដំណឹងថាល្អនោះមិនពិតទេ ។ បើប្រាប់ដំណឹងថាអាក្រក់នោះពិតទៅវិញ ។ បើទៅរកយុវនាង មិនល្អទេ ។ បើមើលពីរបស់បាត់ ទាយថាមនុស្សសម្បុរខ្មៅលួចយក មានស្នាមយ៉ាងច្បាស់នៅមុខ និងក្បាល របស់នោះបាត់សោះហើយ ។ បើមើលពីការឈឺថ្កាត់ទាយថាៈ ត្រូវខ្មោចតៃហោងឱ្យទោស ។ បើដើរដំណើរទៅផ្លូវឆ្ងាយ តើកាលណានឹងមកវិញ? ទាយថាបីថ្ងៃទៀតមកហើយ បើកន្លងពីនោះទៅ លុះតែយូរទើបបានមកដល់ ។ បើទៅធ្វើសឹកសង្គ្រាមនឹងមានជ័យជំនះ ។ បើជល់មាន់ទាយថា មាន់សម្បុរសចាញ់, មាន់ខ្មៅឈ្នះ ។ បើក្តាប់ឈើខ្លីវែង ឱ្យទាយថាដៃស្តាំខ្លី ដៃ

ឆ្វេងវែង ។ បើក្តាប់ឈើគូ ឬឥតគូ ឱ្យទាយថាគូ ។ បើវាយគ្នា ថាមានរបួសជាទម្ងន់ ។ នេះជា **យាមកាលា** ។ចប់។

៣. បើត្រូវលើ **យាមសី** ទោះនឹងចរលីលា មានស្រីសម្បុរសឱ្យលាភយ៉ាងគាប់ចិត្ត បានក្នុងថ្ងៃនោះឯង ហើយសិទ្ធតែរបស់ស ។ បើមើលពីរបស់បាត់ ទាយថាមនុស្សស្រីសម្បុរសលួច និងក្មេងសស្អាតលួចយកទៅទិសនិរតី នៅក្នុងយាមសីថាៈ និងបានឃើញវិញ ។ បើគេប្រាប់ថាល្អ ពិតជាល្អមែន, បើប្រាប់ថាអាក្រក់ កុហក់ទេកុំជឿ ។ បើមើលពីដំណើរ ថាកាលណាមកវិញ ទាយថាព្រឹកមកវិញហើយ, បើសិនជាទៅរកយុននាង ពេលនេះល្អណាស់ កុំសង្ស័យអ្វី ។ បើទៅរកមិត្តសំឡាញ់ នឹងបានលាភ ។ បើជល់មាន់ មាន់ខ្មៅចាញ់មាន់ស  បើដាក់មាន់បែរទៅទិសបស្ចឹម ។ បើក្តាប់ឈើវែងខ្លី ទាយថាៈ ដៃស្តាំខ្លី ដៃឆ្វេងវែង ។ បើទាយគូ ឬសេស ថាគូ ។ បើទាយពីច្បាំងគ្នាថា មានរបួសនៅត្រង់ពោះ ។ បើមនុស្សរត់ចាកចេញ ឱ្យមនុស្សស្រីតាមរកទើបទាន់ ។ នេះជា **យាមសី** ។ចប់។

៤. បើបានលើ **យាមព្រហ្ម** យាត្រាប្រាថ្នាការអ្វីៗ មិនបានឡើយ ។ បើចេញទៅធ្វើសិកសត្រូវនឹងលំបាកណាស់ បើមិនដូច្នោះទេ មិត្តភគ្រដែលទៅជាមួយ នឹងកើតវិវាទឈ្លោះគ្នាឯង ។ បើប្រទះនឹងសត្រូវ, សត្រូវនោះសម្បុរដំដែង ។ បើបានរបស់ស៊ី, របស់នោះសុទ្ធតែស ។ បើគេប្រាប់ដំណឹងថាល្អ, កុហក់ទេ ។ បើគេប្រាប់ថាអាក្រក់, ពិតជាអាក្រក់ ។ បើមើលពីទ្រព្យបាត់, ទាយថាៈ មនុស្សសម្បុរដំដែង សក់ក្រហម ភ្នែកស្លឹប ជាមនុស្សដំរើចលួចយក ឃើញមិនឃើញស្មើគ្នា ។ បើទៅរកនាម៉ឺនយុននាង, ទៅទិសបូព៌បានល្អ និងបានរបស់ជាឧត្តមៗ បើទៅរកមិត្តភគ្រ, នោះមិនល្អទេ ។ បើគេមករកយើងវិញ, ទើបល្អ ។ បើមើលពីការឈឺថ្កាត់, ថាយូរទើបបាត់ឈឺពីព្រោះស៊ីខុសទំនង (សាច់សត្វជើង ៤) បើស៊ីបានតែសត្វជើងពីរ ។ បើជល់មាន់, មាន់ខៀវចាញ់គេ ។ បើក្តាប់ឈើគូឬសេស, ទំនាយទាយថាគូ ។ បើប្រាប់ដំណឹងថាឈឺ គឺឈឺត្រង់ពោះ ។ បើមើលពីដំណើរ ថាមកថ្ងៃនេះ ។ បើមិនដូច្នោះទេ បីថ្ងៃទៀតទើបមកដល់ ។ នេះទំនាយ **យាមព្រហ្ម** ។ចប់។

៥. បើបានលើយាម **វិសុជ្ជនូ** បើមានរបស់បាត់ទាយថាៈ មនុស្សប្រុសមានស្នាមខាងឆ្វេង យ៉ាងច្បាស់ វាលួចយកទៅទុកនៅក្រោមដើមឈើធំ ប្របច្រាំងទឹកហូរ បើពុំនោះវាយកទៅទុកនៅផ្ទះចាស់មួយ ឱ្យខំប្រឹងរកទើបបានឃើញ ។ បើមនុស្សរត់, ចេញទៅទិសខាងជើង អាស្រ័យនៅផ្ទះមនុស្សសម្បុរដំដែង ខំតាមរកទើបបានទាន់ ។ បើប្រាប់ដំណឹងថាអាក្រក់នោះពិត, បើប្រាប់ដំណឹងល្អនោះកុហក់ទេ ។ ទោះទៅរកចៅហ្វាយនាយ គេនឹងកើតខឹងក្រោធនឹងយើង ។ បើឈឺថាខ្មោចតែហោងឱ្យទោស, បើស្រីឈឺទើបឆាប់ជា ។ បើចេញទៅលក់ដូរខាតទ្រព្យ ។ បើក្តាប់ឈើខ្លី ឬវែងទាយថា ដៃស្តាំខ្លី, ដៃឆ្វេងវែង ។ បើទាយពីគូ ឬសេស ថាសេស ។ បើមានរបួស ច្រើនៅត្រង់ស្នែង ។ បើជល់មាន់, មាន់សចាញ់គេ មាន់ខ្មៅឈ្នះ ។ បើលេងល្បែងឯទៀតៗ ក៏ដូចគ្នាដែរ ។ នេះជាទំនាយតាមយាម **វិសុជ្ជនូ** ។ ចប់ ។ ក្បួនតាមជំនាយបុរាណ ចប់តែប៉ុណ្ណោះឯង៍ហោង៍ ៕✎

## ជង្គើមថ្ងៃស្លាប់ - រស់

| ជង្គើមរស់ | | | ជង្គើមស្លាប់ | |
|---|---|---|---|---|
| ថ្ងៃ អាទិត្យ | ជង្គើមរស់នៅទិស | ឧត្តរ | ជង្គើមស្លាប់នៅទិស | ទក្សិណ |
| ថ្ងៃ ចន្ទ | ជង្គើមរស់នៅទិស | និរតី | ជង្គើមស្លាប់នៅទិស | ឧត្តរ |
| ថ្ងៃ អង្គារ | ជង្គើមរស់នៅទិស | ឦសាន | ជង្គើមស្លាប់នៅទិស | និរតី |
| ថ្ងៃ ពុធ | ជង្គើមរស់នៅទិស | ឦសាន | ជង្គើមស្លាប់នៅទិស | និរតី |
| ថ្ងៃ ព្រហស្បតិ៍ | ជង្គើមរស់នៅទិស | បូព៌ | ជង្គើមស្លាប់នៅទិស | បស្ចិម |
| ថ្ងៃ សុក្រ | ជង្គើមរស់នៅទិស | អគ្នេយ៍ | ជង្គើមស្លាប់នៅទិស | ពាយព្យណ៍ |
| ថ្ងៃ សៅរ៍ | ជង្គើមរស់នៅទិស | ទក្សិណ | ជង្គើមស្លាប់នៅទិស | ឧត្តរ |